## ការបង្ហាអំពីប្រល័យពូជសាសន៍ : គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
## វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិស្តីពីការបង្រៀនប្រវត្តិសាស្ត្រ
## កម្ពុជាប្រជាធិបតេយ្យនៅថ្នាក់មធ្យមសិក្សា

២៩ មិថុនា-៧ កក្កដា ២០០៩

បណ្ណាល័យព្រឹទ្ធសភា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# ទស្សនៈបែបវិភាគ : សិល្បៈនៃការចោទសួរបែបសូក្រាត ផ្នែក២

**លីនដា អេលឌឺ និងរីឆាត ផូល**

ផ្នែកចុងក្រោយនេះលើកឡើងអំពីទស្សនៈនៃការចោទសួរបែបសូក្រាត ដែលត្រូវបានពិនិត្យមើលចេញពីទស្សនៈនៃការគិតបែបវិភាគ ។ បន្ទាប់មក ផ្នែកនេះផ្តោតទៅលើសំណួរទាំងឡាយដែលមនុស្សម្នាក់ៗអាចសួរក្នុងការវិភាគទៅលើហេតុផលៈ គោលបំណងរបស់ហេតុផល សំណួរដែលត្រូវចោទសួរ ព័ត៌មានដែលត្រូវប្រើប្រាស់ ជំនឿដែលមិនសូវបានគិតដល់ឬសន្មតទុក ទស្សនៈដែលភ្ជាប់ជាមួយហេតុផល ទស្សនៈដែលបង្ហាញហេតុផល ការនិយាយសំដៅទៅរក និងការជាប់ពាក់ព័ន្ធរបស់ហេតុផល ។

ផ្នែកនេះផ្តោតទៅលើសំណួរដែលកំណត់ទិសដៅទៅលើការវាយតម្លៃទៅលើហេតុផល ។ ផ្នែកនេះរួមមានបញ្ជីត្រួតពិនិត្យចំពោះសំណួររបស់សូក្រាត ដែលអាចត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃទៅលទ្ធភាពសួរសំណួររបស់សិស្ស ។

*ការចាត់ថ្នាក់ទៅលើសំណួរបែបសូក្រាត ដោយផ្អែកលើហេតុផលដែលបានវាយតម្លៃ*

*សំណួរដែលដៅទៅលើគុណភាពនៃការឲ្យហេតុផល*

បទដ្ឋានបញ្ញវន្តជាសកលគឺជាបទដ្ឋានដែលការគិតត្រូវបានវិនិច្ឆ័យដោយបុគ្គលមានការអប់រំនិងមានហេតុផល ។ ក៏ប៉ុន្តែមនុស្សភាគច្រើនមិនបានដឹងអំពីបទដ្ឋានទាំងអស់នេះទេ ។ បទដ្ឋានទាំងនេះរួមមាន ការបញ្ជាក់ ភាពជាក់លាក់ ភាពត្រឹមត្រូវ ភាពពាក់ព័ន្ធ ជម្រៅ ភាពដែលអាចវាស់វែងបាន ភាពមានហេតុផល និងយុត្តិធម៌ ។ អ្នកគិតប្រកបដោយជំនាញបានប្រើបទដ្ឋានបញ្ញវន្តជារៀងរាល់ថ្ងៃ ។ អ្នកទាំងនោះបានទទួលស្គាល់ថា នៅពេលដែលអ្នកដទៃ ឬអ្នកទាំងនោះខ្លួនឯងផ្ទាល់ កំពុងប្រើប្រាស់

បទដ្ឋានទាំងអស់នោះ ។ ជាទម្លាប់ អ្នកទាំងនោះបានសួរសំណួរជាក់លាក់សំដៅទៅលើបទដ្ឋានបញ្ញវ័ន្តនេះ ។

នៅខាងក្រោមគឺជាលំនាំមួយចំនួនសម្រាប់ផ្ដើការវាយតម្លៃទៅលើការគិត រួមជាមួយនឹងសំណួរពីសំណាក់អ្នកគិតប្រកបដោយវិន័យ សំណួរដែលត្រូវបានប្រើប្រាស់នៅក្នុងការពិភាក្សារបស់សូក្រាត ។

១. **ភាពច្បាស់លាស់របស់សំណួរ** ៖ ទទួលស្គាល់ថា ជានិច្ចកាល ការគិតគឺតែងតែមានភាពច្បាស់លាស់ខ្លាំងឬតិចតួច ។ សន្មតថា គ្មានការគិតណាមួយត្រូវបានយល់ទាំងស្រុងនោះទេ លើកលែងតែការការគិតនោះមានភាពលម្អិតដែលបង្ហាញច្បាស់លាស់និងជាក់ស្ដែង ។

សំណួរដែលផ្ដោតទៅលើភាពច្បាស់លាស់នៅក្នុងការគិតរួមមាន ៖

- តើអ្នកគិតបានពិនិត្យល្អិតល្អន់ទៅលើប្រធានបទឬអត់?

- តើអ្នកនោះអាចផ្ដល់នូវឧទាហរណ៍ឬការបង្ហាញដល់ចំណុចដែរឬអត់?

- តើសារដែលបានបង្ហាញចេញនោះគឺជា “........” ។ តើការយល់បែបនោះត្រឹមត្រូវដែរឬទេ?

២. **ការសួរពីភាពច្បាស់លាស់** ៖ ដោយទទួលស្គាល់ថា ជានិច្ចកាល ការគិតមានភាពច្បាស់លាស់តិចឬច្រើន ។ សន្មតថា គ្មានការគិតណាមួយអាចត្រូវបានយល់ទាំងស្រុងនោះទេ លើកលែងតែកម្រិតមួយដែលអ្នកនោះអាចបញ្ជាក់ក្នុងន័យលម្អិត ។ សំណួរដែលផ្ដោតទៅលើភាពច្បាស់លាស់នៅក្នុងការគិតរួមមាន ៖

- តើអ្នកគិតផ្ដល់នូវភាពលម្អិតអំពីប្រធានបទនោះដែរឬទេ?

- តើការគិតនោះអាចផ្ដល់ភាពជាក់លាក់បន្ថែមទៀតឬទេ?

- តើអ្នកនោះអាចបញ្ជាក់ច្បាស់អំពីការចោទប្រកាន់ដោយពេញលេញដែរឬទេ?

៣. **ការចោទសួរទៅលើភាពត្រឹមត្រូវ** ៖ ដោយទទួលស្គាល់ថា ជានិច្ចកាលគឺការគិតមានភាពត្រឹមត្រូវតិចឬច្រើន ។ សន្មតថា គ្មានការគិតណាមួយត្រូវបានវាយតម្លៃឲ្យបានពេញលេញនោះទេ លើកលែងតែក្នុងកម្រិតមួយដែលមនុស្សម្នាក់បានត្រូវពិនិត្យដើម្បីកំណត់ថាតើការគិតនោះតំណាងឲ្យរឿងគ្រប់បែបយ៉ាង ។ សំណួរដែលផ្ដោតលើភាពត្រឹមត្រូវនៅក្នុងការគិត រួមមាន ៖

- តើមនុស្សម្នាក់អាចត្រូវពិនិត្យភាពត្រឹមត្រូវនោះដើម្បីពិចារណាថាតើវាត្រឹមត្រូវឬទេ?

- តើមនុស្សម្នាក់អាចផ្ទៀងផ្ទាត់អំពីអង្គហេតុពិតដែលមានការចោទប្រកាន់ដែរឬទេ?

- តើភាពត្រឹមត្រូវនៃទិន្នន័យទាំងអស់នោះមានតម្លៃដែរឬទេ បើពិនិត្យមើលទៅលើប្រភពដែលគួរឲ្យសង្ស័យនោះ?

៤. **ការចោទសួរអំពីភាពពាក់ព័ន្ធ** ៖ ដោយទទួលស្គាល់ថា ជានិច្ចកាលការគិតមានលទ្ធភាពងាកចេញអំពីភារកិច្ច សំណួរ បញ្ហា ឬរឿងរ៉ាវដែលស្ថិតក្រោមការពិចារណា ។ សន្មតថាគ្មានការគិតណាមួយត្រូវបានវាយតម្លៃឲ្យពេញលេញនោះទេ លើកលែងតែក្នុងការកម្រិតមួយដែលមនុស្សម្នាក់ៗ បានធានាថា ការពិចារណាទាំងឡាយដែលប្រើនៅក្នុងការដោះស្រាយបញ្ហា មានភាពជាប់ពាក់ព័ន្ធគ្នា ពិតប្រាកដជាមួយនឹងបញ្ហានោះ ។ សំណួរដែលផ្តោតទៅលើភាពជាប់ពាក់ព័ន្ធនៅក្នុងការគិតរួមមាន ៖

- តើការគាំទ្រដែលទទួលបានមាននៅក្នុងសំណួរដែរឬអត់? តើវាពាក់ព័ន្ធគ្នាយ៉ាងដូចម្តេច?
- សូមពន្យល់អំពីទំនាក់ទំនងរវាងចេតនាដែលមានការគាំទ្រនិងសំណួរដែលត្រូវបានផ្តោតទៅលើ

៥. **ការចោទសួរអំពីជម្រៅ** ៖ ទទួលស្គាល់ថា ការគិតអាចមានតួនាទីនៅផ្នែកខាងលើនៃរឿងរ៉ាវទាំងឡាយឬចូលដល់ស៊ីជម្រៅពីផ្នែកខាងលើរហូតដល់បញ្ហាឬរឿងរ៉ាវជ្រៅថែមទៀត ។ សន្មតថា គ្មានការគិតណាមួយត្រូវបានវាយតម្លៃទាំងស្រុងនោះទេ លើកលែងតែអ្នកនោះបានកំណត់អំពីជម្រៅ ដែលតម្រូវសម្រាប់ភារកិច្ចនៅក្នុងដៃ (ហើយប្រៀបធៀបវាជាមួយនឹងជម្រៅដែលត្រូវសម្រេចបានជាក់ស្តែង) ដើម្បីពិនិត្យមើលថាតើសំណួរនោះមានភាពស៊ីជម្រៅ និងកំណត់ថាតើវាជាប់ពាក់ព័ន្ធនឹងភាពសាំញ៉ាំដែលត្រូវពិនិត្យពិចារណាដែរឬអត់ ។ សំណួរដែលត្រូវផ្តោតលើភាពស៊ីជម្រៅរួមមាន ៖

- តើសំណួរនោះមានលក្ខណៈធម្មតាឬសាំញ៉ាំ? តើសំណួរនោះងាយស្រួលឬពិបាកឆ្លើយ?
- តើអ្វីដែលធ្វើឲ្យសំណួរនោះមានភាពសាំញ៉ាំ?
- តើភាពសាំញ៉ាំដែលភ្ជាប់ជាមួយនៅក្នុងសំណួរដែលត្រូវបានដោះស្រាយមានលក្ខណៈយ៉ាងដូចម្តេច?

៦. **ការចោទសួរអំពីទំហំ** ៖ ដោយទទួលស្គាល់ថា ការគិតមានលក្ខណៈទូលំទូលាយច្រើនឬតិច (ឬការគិតបែបចង្អៀតចង្អល់) ហើយថា ទំហំនៃការគិតតម្រូវឲ្យអ្នកគិតអាចគិតច្បាស់លាស់នៅក្នុងទស្សនៈលើសពីមួយឬក្របខ័ណ្ឌនៃសេចក្តីយោង ។ សន្មតថា គ្មានការគិតណាមួយត្រូវបានវាយតម្លៃទាំងស្រុងនោះទេ លើកលែងតែក្នុងកម្រិតមួយដែលមនុស្សម្នាក់ៗអាចកំណត់ថាតើទំហំនៃការគិតប៉ុនណាដែលតម្រូវឲ្យមាន (ហើយទំហំប៉ុនណាត្រូវបានយកមកអនុវត្ត) ។ សំណួរដែលផ្តោតទៅលើទំហំនៃការគិតរួមមាន ៖

- តើទស្សនៈអ្វីខ្លះដែលជាប់ព័ន្ធទៅនឹងបញ្ហានេះ?
- តើទស្សនៈជាប់ពាក់ព័ន្ធអ្វីខ្លះដែលត្រូវបានបំភ្លេចចោលនាពេលកន្លងមក?

- តើទស្សនៈវិស័យជំទាស់ត្រូវបានទុកចោលមិនពិចារណាដោយសារតែគ្មានសុឆន្ទៈផ្លាស់ប្តូរទស្សនៈផ្ទាល់ខ្លួន?

- តើមានទស្សនៈជំទាស់ត្រូវបានពិចារណាក្នុងន័យល្អឬគ្រប់គ្រាន់ល្មមដើម្បីរកឲ្យឃើញពីភាពខុះចន្លោះនៅក្នុងទស្សនៈនោះដែរឬទេ?

- តើភាពទទួលខុសត្រូវខាងក្រមសីលធម៌ក្នុងការពិនិត្យមើលទៅលើបញ្ហាចេញពីទស្សនវិស័យសេដ្ឋកិច្ចយ៉ាងដូចម្តេច?

- តើអ្វីជាតួនាទីបែបសេរីទៅលើបញ្ហានេះ? តើអ្វីដែលគំនិតអភិរក្សនិយមគួរតែនិយាយ?

## សិល្បៈនៃបញ្ជីត្រួតពិនិត្យសំណួរបែបសូក្រាត

បញ្ជីខាងក្រោមនេះអាចត្រូវបានប្រើប្រាស់ដើម្បីជំរុញឲ្យមានការចោទសួរប្រកបដោយវិន័យពីសំណាក់សិស្សានុសិស្ស ។ សិស្សអាចដាក់វេនដឹកនាំការពិភាក្សាជាក្រុមអំពីសូក្រាត ។ ក្នុងអំឡុងពេលធ្វើកិច្ចការនេះ សិស្សខ្លះអាចត្រូវបានសួរដើម្បីអង្កេតទៅលើអ្នកដែលដឹកនាំការពិភាក្សាហើយផ្តល់នូវទស្សនៈយល់ឃើញដោយប្រើប្រាស់លំនាំខាងក្រោម (ដែលសិស្សទាំងអស់គួរតែមានលំនាំនេះម្នាក់មួយច្បាប់ក្នុងអំឡុងពេលពិភាក្សា) ។

១ តើអ្នកដឹកនាំការពិភាក្សាបានឆ្លើយតបសំណួរទាំងអស់ដោយមានសំណួរបន្ថែមដែរឬទេ? (ចូរចងចាំថា អ្នកសួរសំណួរតែងតែចង់បានការឆ្លើយតបសំណួរដោយរួមមានទាំងសំណួរផ្សេងទៀត ។ អ្នកសួរសំណួរមិនគួរផ្តល់ទស្សនៈយល់ឃើញរបស់ខ្លួនឡើយ)

### ការរក្សាអ្នកចូលរួមដោយផ្តោតទៅលើធាតុផ្សំនៃគំនិត

១. តើអ្នកសួរធ្វើឲ្យគោលបំណងនៃការពិភាក្សាច្បាស់លាស់ឬអត់? (តើអ្វីជាគោលបំណងហើយនិងលទ្ធផលបញ្ចប់នៅក្នុងការពិភាក្សានេះ?)

២. តើអ្នកសួរសំណួរតាមរកព័ត៌មានដែលពាក់ព័ន្ធដែរឬទេ?
(តើព័ត៌មានអ្វីខ្លះត្រូវបានផ្អែកលើការពិភាក្សា? តើបទពិសោធន៍អ្វីដែលធ្វើឲ្យអ្នកសួរមានការជឿជាក់?)

៣. តើអ្នកសួរចោទសួរទៅលើការនិយាយ ការបកស្រាយ និងសេចក្តីសន្និដ្ឋាន ដែលមានលក្ខណៈសមស្របនិងសំខាន់? (តើអ្នកចោទសួរបានឈានទៅរកសេចក្តីសន្និដ្ឋានយ៉ាងដូចម្តេច? សូមពន្យល់ហេតុផល ។ តើមានការបកស្រាយជាយថាហេតុណាមួយផ្សេងទៀតទេ?

៤. តើអ្នកចោទសួរផ្តោតទៅលើគំនិតឬទស្សនៈសំខាន់ៗដែរឬទេ? (តើអ្វីជាគំនិតសំខាន់ដែលរៀបចំឡើង? សូមពន្យល់គំនិតទាំងអស់នោះ) ។

៥. តើអ្នកចោទសួរបានកត់សម្គាល់ពីការសន្មតដ៏គួរឲ្យសង្ស័យដែរឬទេ?

(តើអ្វីដែលត្រឹមត្រូវនៅត្រង់ចំណុចនេះពិតប្រាកដ? ហេតុអ្វី?)

៦. តើអ្នកសួរសំណួរចោទសួរអំពីភាពជាប់ពាក់ព័ន្ធនឹងផលវិបាកដែរឬទេ?

(តើអ្វីដែលជាន័យបង្កប់...? ប្រសិនបើអ្នកទាំងឡាយទទួលយកសេចក្តីសន្និដ្ឋាននេះ តើអ្វីជាភាពជាប់ពាក់ព័ន្ធបន្ទាប់?

៧. តើអ្នកសួរសំណួរបានចាប់អារម្មណ៍ទៅលើទស្សនៈដែលភ្ជាប់ទៅនឹងចម្លើយផ្សេងៗ?

(តើទស្សនៈអ្វីដែលត្រូវបានសន្មត? តើមានទស្សនៈផ្សេងទៀតសក្តិសមនឹងការពិចារណានេះឬទេ?

៨. តើអ្នកសួរសំណួររក្សាសំណួរសំខាន់នៅក្នុងការផ្តោតអារម្មណ៍ដែរឬទេ?

(តើបញ្ហាអ្វីដែលត្រូវបានបញ្ជូនមកយ៉ាងពិតប្រាកដ? សូមពន្យល់បញ្ហានោះ ។ ចូរចងចាំថាសំណួរនៅក្រោមការពិចារណាគឺ...)

៩. តើអ្នកសួរសំណួរសុំឲ្យមានការបញ្ជាក់នូវបរិបទនៅពេលណាចាំបាច់ដែរឬអត់?

(សូមផ្តល់ព័ត៌មានបន្ថែមអំពីហេតុការណ៍ដែលលេចឡើងនូវបញ្ហានេះ ។ តើអ្វីបានកំពុងកើតឡើងនៅក្នុងស្ថានភាពនេះ?)

**ការធ្វើឲ្យអ្នកចូលរួមផ្តោតលើប្រព័ន្ធនៃការគិត**

១. តើអ្នកសួរសំណួរបានបែងចែកសំណួរបែបអត្តនោម័តចេញពីសំណួរដែលបង្កប់នូវការពិតចេញពីសំណួរទាំងឡាយដែលទាមទារនូវការវិនិច្ឆ័យសមហេតុផលនៅក្នុងទស្សនៈផ្ទុយគ្នាដែរឬទេ?

(តើសំណួរនេះកំពុងទាមទារឲ្យមានជម្រើសបែបអត្តនោម័តឬផ្ទាល់ខ្លួនដែរឬទេ? ប្រសិនបើដូច្នេះ ចូរធ្វើឲ្យជម្រើសបែបនោះក្លាយជាចង់បានផ្ទាល់ខ្លួន ។ បើមិនដូច្នេះទេ តើមានវិធីផ្សេងទៀតដែលលេចឡើងនូវចម្លើយត្រឹមត្រូវតែមួយគត់ចំពោះសំណួរនេះឬទេ? ឬ តើជាសំណួរដែលនឹងមានចម្លើយខុសៗគ្នានៅក្នុងទស្សនៈខុសៗគ្នាដែរឬទេ? ប្រសិនបើទាក់ទងនឹងសំណួរខាងក្រោយនេះ តើចម្លើយបែបណាប្រសើរជាងគេចំពោះសំណួរនេះ ដែលគ្រប់រឿងរ៉ាវទាំងអស់ត្រូវបានពិចារណា?)

២. តើអ្នកសួរសំណួរធ្វើឲ្យអ្នកចូលរួមយល់ដឹងអំពីវិធីផ្សេងៗទៀត ក្នុងការគិតអំពីបញ្ហាដែរឬទេ

(តើមានវិធីផ្សេងទៀតក្នុងការគិតអំពីបញ្ហានេះឬទេ?)

**ការធ្វើឲ្យអ្នកចូលរួមផ្តោតលើស្តង់ដារគំនិត**

១.តើអ្នកសួរសំណួរស្នើសុំឲ្យមានការបកស្រាយច្បាស់លាស់ នៅពេលចាំបាច់ដែរឬទេ?

(សូមបញ្ជាក់លម្អិតបន្ថែមឬផ្តល់ឧទាហរណ៍ ឬការបង្ហាញលើចំណុចនោះ ។ ការយល់ឃើញរបស់ខ្ញុំគឺ... ។ តើការបកស្រាយរបស់ខ្ញុំត្រឹមត្រូវដែរឬទេ?)

២. តើអ្នកសួរសំណួរសុំឲ្យមានព័ត៌មានលម្អិតបន្ថែមទៀតឬភាពច្បាស់លាស់ជាងនេះ នៅពេលចាំបាច់ឬទេ?

(សូមផ្តល់ព័ត៌មានលម្អិតបន្ថែមទៀតអំពីចំណុចនោះ ។ តើការចោទប្រកាន់មានបញ្ហាច្បាស់ពេញលេញជាងនេះទេ?)

៣. តើអ្នកសួរសំណួរធ្វើឲ្យអ្នកចូលរួមឆាប់ចង់បានចំពោះតម្រូវការដើម្បីត្រួតពិនិត្យការពិត និងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័ត៌មានដែរឬទេ?

(តើសុពលភាពអាចត្រូវពិនិត្យដែរឬទេ? តើការពិតតាមការចោទប្រកាន់ត្រូវបានផ្ទៀងផ្ទាត់ដែរឬទេ?

៤. តើអ្នកសួរសំណួរធ្វើឲ្យអ្នកចូលរួមយល់ដឹងអំពីតម្រូវការដែលភ្ជាប់ទៅនឹងសំណួរកំពុងពិភាក្សា ដើម្បីធ្វើឲ្យប្រាកដថា "ចម្លើយ" របស់ពួកគេជាប់ពាក់ព័ន្ធទៅនឹងសំណួរដែលកំពុងធ្វើការដោះស្រាយនៅក្នុងពេលណាមួយដែលត្រូវបានផ្តល់ឲ្យដែរឬទេ?

(តើចំណុចខាងលើនេះជាប់ពាក់ព័ន្ធចំពោះសំណួរយ៉ាងដូចម្តេះ? សូមពន្យល់ការជាប់ទាក់ទងគ្នានេះ ។

៥. តើអ្នកសួរសំណួរធ្វើឲ្យអ្នកចូលរួមដឹងច្បាស់អំពីភាពសាំញ៉ាំនៅក្នុងសំណួរនៅពេលមានការពិភាក្សាដែរឬទេ? តើអ្នកសួរសំណួរបានសុំឲ្យអ្នកចូលរួមគិតទៅលើបញ្ហានោះ កាន់តែស៊ីជម្រៅដែរឬទេ?

(តើអ្វីដែលធ្វើឲ្យបញ្ហានោះមានភាពសាំញ៉ាំ? តើចម្លើយនោះធ្វើឲ្យមានការពិចារណាទៅលើភាពសាំញ៉ាំនៅក្នុងសំណួរដែរឬទេ?)

៦. តើអ្នកសួរសំណួរធ្វើឲ្យអ្នកចូលរួមយល់ដឹងអំពីទស្សនៈច្រើនបែបនៅពេលឆ្លើយទៅនឹងសំណួរទូលំទូលាយ?

(ជារឿងសំខាន់ណាស់ដែលត្រូវពិនិត្យមើលទៅលើបញ្ហាចេញពីទស្សនៈ វិស័យសេដ្ឋកិច្ចនិងទស្សនៈវិស័យក្រមសីលធម៌ ។ តើអ្វីដែលអ្នកសេរីនិងអ្នកអភិរក្សនិយាយអំពីបញ្ហានេះ? យើងបានពិនិត្យមើលអំពីអ្វី ដែលអ្នកគិតឃើញអំពីសភាពការណ៍ ក៏ប៉ុន្តែអ្វីដែលឪពុកម្តាយរបស់អ្នកយល់ឃើញដែរ?

## ការធ្វើឲ្យអ្នកចូលរួមចូលប្រឡូកក្នុងការពិភាក្សាយ៉ាងក្លៀវក្លា

១. តើអ្នកចោទសួរគិតឃើញយ៉ាងម៉េចជាមួយនឹងអ្នកចូលរួម?

២.តើអ្នកចោទសួរទុកពេលឲ្យគ្រប់គ្រាន់សម្រាប់អ្នកចូលរួមក្នុងការរកចម្លើយដែរឬទេ?

៣. តើអ្នកចោទសួរធានាឲ្យប្រាកដថា រាល់ការរួមចំណែកនីមួយៗត្រូវបានដោះស្រាយយ៉ាងត្រឹមត្រូវ តាមទស្សនៈផ្សេងៗគ្នាដែរឬទេ?

៤. តើអ្នកចោទសួរបានសង្ខេបខ្លឹមសារខណៈពេលដែលការពិភាក្សាកំពុងស្ថិតក្នុងរបៀបវារៈរបស់ខ្លួន? តើអ្វីដែលជាសំណួរ ហើយ សំណួរអ្វីខ្លះដែលមិនទាន់ឆ្លើយ?

៥. តើការពិភាក្សាបានបន្តដោយរលូន ដោយមានការចូលរួមផ្សេងៗគ្នាប្រកបដោយប្រសិទ្ធភាពដែរឬទេ?

## សេចក្តីសន្និដ្ឋាន

ផ្នែកនេះបានផ្តោតទៅលើសំណួរជាក់លាក់មួយចំនួន ដែលគ្រូ និងសិស្សអាចសួរដើម្បីធ្វើឲ្យយល់ វិភាគ វាយតម្លៃ និងអង្កេតមើលទៅលើការគិត។ ផ្នែកបន្ទាប់នឹងបន្តផ្តល់កន្លែងសំរាប់ការចោទសួរសំណួររបស់សូក្រាត ដោយប្រើប្រាស់ការគិត និងគោលការណ៍ប្រកបដោយការវិភាគ។ បើទោះជាយុត្តិសាស្រ្ត ដែលយើងលើកមកនិយាយនៅក្នុងផ្នែកនេះ មានភាពសំខាន់យ៉ាងខ្លាំងក៏ដោយ ជាការសំខាន់ដែលយើងទទួលស្គាល់ថាការវិវត្តអំពីសមត្ថភាពនៃការចោទសួររបស់សូក្រាត បានបង្កើតឡើងក្នុងកំរិតពេលវេលាដែលបានទុកឲ្យ និងតាមរយៈការប្តេជ្ញាចិត្តក្នុងការអនុវត្តន៍។ ជាងនេះទៅទៀតការវិវត្តជំនាញទាំងអស់នេះសន្មតទុក ជាមុននូវការយល់ដឹងដ៏ស៊ីជម្រៅចំពោះទ្រឹស្តីនៃការគិតបែបវិភាគដែលបង្កប់វិធីសាស្រ្តចោទសួរបែបសូក្រាត។ សូក្រាតផ្ទាល់បានចំណាយពេលក្នុងជីវិតរបស់គាត់ដើម្បីអភិវឌ្ឍន៍ជំនាញរបស់គាត់ ក្នុងការសួរសំណួរដ៏ស៊ីជម្រៅ និងប្រកបដោយផ្លែផ្កា។ នៅចុងបញ្ចប់នៃជីវិតរបស់គាត់ គាត់បាននិយាយថាគាត់បានត្រឹមតែចាប់ផ្តើមយល់អំពីសិល្បៈនៃការសួរសំណួរតែប៉ុណ្ណោះ។